# មេរៀនទី ២៤៖ អ្នកយាមគុកទទួលជឿព្រះយេស៊ូវ

កិច្ចការ ១៦៖១៦-៣៤

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/lyNxdGqrX-w

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/dM5stOEwo_U

**គោលបំណង៖** ព្រះប្រើអំណាចរបស់ទ្រង់ដើម្បីមកជួយរំដោះយើង

**ខគម្ពីរចងចាំ៖** កិច្ចការ១៦៖៣១ *"...ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះ ហើយព្រមទាំងពួកគ្រួសារលោកផង"។*

**ចំរៀង** ( *យូធូបលីង* )៖

១. សរសើរព្រះយេស៊ូវ https://youtu.be/uA448Ncse8Q

២. ខ្ញុំសប្បាយរីករាយ https://youtu.be/2LWPsq-KZvo

៣. ខ្ញុំនិងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

**១. អធិស្ឋាន**

**២. ចំរៀង** ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

**៣. ល្បែងកំសាន្ត** «សូមប្រុងប្រៀបខ្លួន!»

សម្ភារៈដែលត្រូវការ៖ ប៉េងប៉ោង



១.ពេលកុមារចូលមកខាងក្នុងថ្នាក់ ឲ្យពួកគេនិយាយគ្នាឮៗ ហើយរញ៉េរញ៉ៃតាមតែគេទៅ។

២.បន្ទាប់មកគ្រូយកប៉េងប៉ោងមកហើយបំបែកវា! ពេលនេះកុមារនឹងបែរមកចាប់អារម្មណ៍ជាមួយគ្រូវិញហើយ។

៣.សួរកុមារថាហេតុអ្វីបានជាពួកគេបែរមកចាប់អារម្មណ៍ជាមួយគ្រូវិញ( ចម្លើយ៖ ព្រោះអ្នកគ្រូធ្វើឲ្យ ប៉េងប៉ោងបែក ហើយធ្វើឲ្យខ្ញុំខ្លាច )

៤. ពន្យល់ដល់កុមារថា ព្រះទាញយកចំណាប់អារម្មណ៍របស់យើង ហើយទ្រង់ឈោងចាប់យើងតាមរយៈវិធីដ៏មានឫទ្ធានុភាពរបស់ទ្រង់ ដូចជារបៀបដែលសំលេងប៉េងប៉ោងបែក អាចទាញយកការចាប់អារម្មណ៍ពីប្អូនៗអីចឹងដែរ។

**៤. ការណែនាំមេរៀន**

តើនៅពេលដែលប៉េងប៉ោងបែកវាធ្វើឲ្យប្អូនៗភ័យដែរឬទេ? ពេលខ្លះព្រះប្រើនូវអំណាចរបស់ទ្រង់ដើម្បីទាញយកចំណាប់អារម្មណ៍របស់យើងចំពោះទ្រង់។ ហេតុអ្វីបានជាព្រះចង់ឲ្យយើងចាប់អារម្មណ៍ចំពោះទ្រង់? ទ្រង់ ចង់ឱ្យយើងដឹងថាទ្រង់ជាព្រះ។ ទ្រង់ចង់ឱ្យយើងដឹងថា ព្រះអង្គស្រឡាញ់យើង។

តើប្អូនធ្លាប់មានអារម្មណ៍ថាព្រះនៅឆ្ងាយពេកក្នុងការយល់ និងជួយដល់ប្អូនៗដែរឬទេ? តើប្អូនធ្លាប់មានអារម្មណ៍ថាប្អូនមានបញ្ហា ហើយព្រះមិនអាចជួយប្អូនបានដែរឬទេ? ប្រសិនបើប្អូនធ្លាប់មានអារម្មណ៍បែបនេះ ត្រូវគិតថាមិនមែនមានតែប្អូនទេ។ ពេលខ្លះ យើងប្រហែលជាមានអារម្មណ៍ថា ព្រះមិនអាចជួយ

យើងបានទេ។ ប៉ុន្តែព្រះអាចជួយដល់ប្អូនបាន ហើយជួនកាលទ្រង់ធ្វើវាតាមរបៀបមិនធម្មតាទៀតផង។ ចូរយើងស្វែងយល់ពីរបៀបដែលព្រះបានប្រើអំណាចរបស់ទ្រង់ ដើម្បីជួយដល់មនុស្សមួយចំនួននៅក្នុងព្រះគម្ពីរ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះប្រាប់យើងអំពីប៉ុល និងស៊ីឡាស ដែលត្រូវបានចាប់ដាក់គុកដោយសារ ការផ្សាយដំណឹងល្អអំពីព្រះយេស៊ូវ។ ពួកគាត់ត្រូវគេវាយដំ និងចោទប្រកាន់ខុសពីការពិតប៉ុន្តែជំនួសដោយការខឹងនិងការកើតទុក្ខពួកគេបែរជាថ្វាយបង្គំព្រះវិញ ។ ទោះបីពួកគេ នៅក្នុងគុកក៏ដោយ ពួកគេច្រៀងសរសើរតម្កើងព្រះពេញមួយយប់ ។ នៅក្នុងព្រះគម្ពីរបានបញ្ជាក់ថា អ្នកយាមគុកនិងអ្នកទោសឯទៀតបានស្តាប់ការច្រៀងសរសើរដម្កើងព្រះរបស់ពួកគាត់។ ហើយរឿងដ៏អស្ចារ្យមួយបានកើតឡើងដោយសារពួកគេជ្រើសរើសសរសើរតម្កើងព្រះ ទោះជានៅក្នុងពេលដែល ពួកគេរងទុក្ខក៏ដោយ!

ព្រះបានធ្វើឲ្យមានការរញ្ជួយដីដ៏ខ្លាំងមួយរហូតធ្វើឲ្យទ្វារគុករបើក ហើយច្រវាក់ដែលដាក់មនុស្សទាំងអស់របូតចេញ។ ពេលអ្នកយាមគុកឃើញដូច្នេះគាត់ភ័យខ្លាំងណាស់។ គាត់ដឹងថាគាត់នឹងត្រូវគេស្តីបន្ទោសពីរឿងដែលអ្នកទោស ទាំងអស់បានរត់គេច ហើយពួកគេនឹងសម្លាប់គាត់ដោយសាររឿងនេះ! ដូច្នេះហើយអ្នកយាមគុកបាន សម្រេចចិត្តសម្លាប់ខ្លួន។ ប៉ុន្តែប៉ុល និងស៊ីឡាសមិនបានរត់គេចទេ។ ពួកគេឃាត់អ្នកយាមគុកមិនឲ្យសម្លាប់ខ្លួន ហើយថែមទាំងប្រាប់គាត់អំពីព្រះយេស៊ូវទៀតផង។ អ្នកយាមគុកបានជឿនូវអ្វីដែលពួកគេនិយាយអំពីព្រះយេស៊ូវ គាត់សប្បាយចិត្តណាស់ដែលបានឮអំពីព្រះយេស៊ូវ ហើយគាត់ក៏បាននាំ ប៉ុល និងស៊ីឡាសទៅជួប ជាមួយក្រុមគ្រួសាររបស់គាត់ទៀតផង។ គ្រប់គ្នាក្នុងគ្រួសាររបស់គាត់បានជឿលើព្រះយេស៊ូវ ហើយទទួលបុណ្យជ្រមុជទឹកផងដែរ។

ព្រះបានប្រើអំណាចរបស់ទ្រង់ដើម្បីបង្ហាញអ្នករាល់គ្នាដែលជាប់គុកថាទ្រង់ជាព្រះពិត! ព្រះបានប្រើនូវអំណាចរបស់ទ្រង់ដើម្បីដោះលែងប៉ុល និងស៊ីឡាសឲ្យមានសេរីភាព។ ប៉ុន្តែ ព្រះក៏បានប្រើអំណាចរបស់ទ្រង់ដើម្បីជួយឆ្មាំគុកឲ្យស្គាល់ព្រះយេស៊ូវផងដែរ។

ព្រះក៏បានប្រើអំណាចរបស់ទ្រង់ដើម្បីជួយដល់យើងផងដែរ។ ពេលខ្លះយើងជួបស្ថានភាពដែលយើងត្រូវការជំនួយពីព្រះយេស៊ូវ។ ប្រហែលជាអ្នកប្អូនណាម្នាក់ដែលអ្នកស្គាល់កំពុងមានជម្ងឺ ហើយត្រូវការការព្យាបាល។ ប្រហែលជាសមាជិកក្នុងគ្រួសាររបស់អ្នកមិនទាន់ស្គាល់ព្រះយេស៊ូវនៅឡើយទេ។ សូម្បីតែនៅពេលដែលអ្នកមានអារម្មណ៍ថា ព្រះដូចជានៅឆ្ងាយពេកក្នុងការជួយដល់អ្នកក៏ដោយ ក៏ព្រះទ្រង់គង់នៅទីនោះជាមួយអ្នកដែរ។ ហើយព្រះនឹងប្រើអំណាចដ៏អស្ចារ្យរបស់ទ្រង់ដើម្បីជួយអ្នក ដូចជាទ្រង់បានធ្វើឲ្យមានការរញ្ជួយដី ដើម្បីជួយដល់ប៉ុល និងស៊ីឡាស ព្រមទាំងជួយអ្នកយាមគុកឲ្យជឿលើព្រះយេស៊ូវដូច្នោះដែរ!

## ៦. សំនួរពិភាក្សា

១. តើអ្នកណាខ្លះត្រូវគេបញ្ជូនទៅក្នុងគុកដោយសារការអធិប្បាយអំពីព្រះយេស៊ូវ? *(ប៉ុល និងស៊ីឡាស)*
២. តើព្រះបានធ្វើអ្វីដើម្បីដោះលែងប៉ុល និងស៊ីឡាស? *(មានកក្រើកដីជាខ្លាំង មានរញ្ជួយដល់ជើងជញ្ជាំងគុកផង ហើយទ្វារទាំងប៉ុន្មានរបើកចេញភ្លាម ខ្នោះក៏ហើបចេញទាំងអស់ទៅ)*
៣.តើអ្នកយាមគុកគាត់បានធ្វើអ្វីបន្ទាប់ពីបានឃើញហេតុការណ៍ទាំងនោះ?
*(គាត់ហូតដាវបំរុងនឹងសំឡាប់ខ្លួនឯងចោល)*

៤. ហេតុអ្វីបានជាឆ្មាំគុកអញ្ជើញ ប៉ុល និងស៊ីឡាសទៅផ្ទះគាត់ បរិភោគអាហារ?
*(ដោយសារគាត់ចង់អរគុណដល់ប៉ុលនិងស៊ីឡាសដែលបានជួយគាត់និងគ្រួសារគាត់អោយបានទទួលជឿលើព្រះយេស៊ូវ)*
៥. តើមនុស្សបានលឺដំណឹងល្អរបស់ព្រះយេស៊ូវតាមរយៈអ្វី? *(គ្រូកុមារ គ្រូគង្វាល ម្តាយ បង ពូ មីង យាយតា វិទ្យុ ។ល។)*
៦. តើមានវិធីអ្វីទៀតដែលព្រះអាចប្រើដើម្បីជួយដល់យើង? *(បញ្ជូនទេវតាមក តាមរយៈព្រះគម្ពីរ តាមរយៈមនុស្សចម្លែកដែលយើងមិនស្គាល់ ឬមិត្តភក្តិ។ល។)*

**៧. ល្បែងកំសាន្ត** «ព្រះជ្រាបដឹង ថាយើងនៅទីណា»



១. ពេលខ្លះមនុស្សវង្វេងចេញពីព្រះ។ ប៉ុន្តែព្រះប្រើអំណាចរបស់ទ្រង់ដើម្បីឈោងចាប់យើង ហើយនាំយើងត្រឡប់មករកទ្រង់វិញ។
២. គ្រូនឹងសម្តែងតួជាព្រះ ហើយក្មេងៗសម្តែងធ្វើជាវង្វេងចេញពីព្រះដោយទៅពួននៅកន្លែងណាមួយនៅក្នុងបន្ទប់
៣. ទុកពេលឱ្យកុមារលាក់ខ្លួននៅក្នុងបន្ទប់ (ពួកគេអាចអង្គុយទល់មុខជញ្ជាំងដោយបិទភ្នែកក៏បាន)។
៤. គ្រូនឹងដើរជុំវិញថ្នាក់រៀន ហើយស្វែងរកកុមារដែលកំពុងលាក់ខ្លួននោះ។ នៅពេលគ្រូហៅឈ្មោះ កុមារណាម្នាក់ កុមារនោះត្រូវជួយអ្នកគ្រូ/លោកគ្រូ ដើម្បីស្វែងរក "កុមារដែលកំពុងពួន" ផ្សេងទៀត។
៥.សូមពន្យល់ដល់កុមារថា សូម្បីតែនៅពេលដែលពួកគេមានអារម្មណ៍ថាវង្វេងក៏ដោយ ក៏ព្រះទ្រង់ជ្រាបច្បាស់ថាពួកគេនៅទីណាដែរ ដូចទៅនឹងរបៀបដែលគ្រូបានដឹងថា កុមារទាំងអស់នៅឯណាអ៊ីចឹង។
៦. កុំភ្លេចថាព្រះជ្រាបថាយើងនៅទីណា ហើយទ្រង់ប្រើអំណាចរបស់ទ្រង់ដើម្បីស្វែងរកយើង។

**៨. ខគម្ពីរចងចាំ**
**កិច្ចការ១៦៖៣១** *"...ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងពួកគ្រួសារលោកផង"*។

**៩. ហត្ថកម្ម** «ផាត់ពណ៌រូបភាព ប៉ុល និងស៊ីឡាស»
សូមបោះពុម្ពរូបភាពឲ្យកុមារផាត់ពណ៌ ហើយសរសេរខគម្ពីរចងចាំនៅលើក្រដាសនោះ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ពេលខ្លះយើងចង់មានបទពិសោធន៍ជាមួយព្រះ ហើយពេលខ្លះយើងមានអារម្មណ៍ថានៅឆ្ងាយពីទ្រង់។ ប៉ុន្តែព្រះគម្ពីរនៅថ្ងៃនេះ បានប្រាប់យើងថាព្រះជាម្ចាស់តែងតែជួយដល់យើង។ ទ្រង់បានបង្កើតឲ្យមានការរញ្ជួយដី ដើម្បីជួយរំដោះប៉ុល និងស៊ីឡាស។ ហើយនៅក្នុងពេលជាមួយគ្នានេះដែរ យើងត្រូវអ្នកដល់ដទៃ ដែលរស់នៅ និងចែកចាយអំពីដំណឹងល្អរបស់ព្រះយេស៊ូវ។ សូមអធិស្ឋានសម្រាប់ក្មេងៗដែលអ្នកនិងបង្រៀនពួកគេនៅក្នុងថ្ងៃនេះ។ ទូលសូមព្រះឲ្យជួយបើកដួងចិត្តរបស់ពួកគេ ដើម្បីទទួលបានពិសោធន៍ថ្មីជាមួយព្រះនៅក្នុងជីវិតរបស់នៅរបស់ពួកគេ។



សូមសរសេរខគម្ពីរចងចាំ: ____________________

____________________________________

____________________________________

____________________________________